# សេចក្តីថ្លែងការណ៍រួម

## ភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៣

## សង្គមស៊ីវិលអំពាវនាវឲ្យគណបក្សនយោបាយលើកកម្ពស់បញ្ហាស្ត្រី និងកុមារបន្ថែមទៀត

នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ក្រុមអង្គការសង្គមស៊ីវិល("សង្គមស៊ីវិល") បានរួមគ្នារៀបចំវេទិកាពិភាក្សាកម្មវិធីនយោបាយថ្នាក់ជាតិស្តីពី "វិធានការពិសេសដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារនៅកម្ពុជា"("វេទិកាពិភាក្សា")។ សង្គមស៊ីវិលសូមស្វាគមន៍ចំពោះការពិភាក្សារបស់តំណាងគណបក្សនយោបាយទាំង៧ក្នុងចំណោមគណបក្សទាំង៨ ដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃអាទិត្យ ទី២៨ កក្កដា ២០១៣។ តំណាងគណបក្សនយោបាយបានបង្ហាញពីគោលនយោបាយរបស់ខ្លួនទាក់ទងនឹងវិធានការពិសេសដើម្បីដោះស្រាយបញ្ហាស្ត្រីនិង កុមារនៅកម្ពុជា ហើយផ្តោតជាពិសេសទៅលើការអនុវត្តប្រព័ន្ធកូតាដើម្បីបង្កើនចំនួនតំណាងស្ត្រីក្នុងនយោបាយ នៅគ្រប់កម្រិតថ្នាក់សម្រេចចិត្ត។

ខណៈដែលគណបក្សនយោបាយមួយចំនួនបានលើកឡើងនូវ យុទ្ធសាស្ត្ររបស់គណបក្សខ្លួនដើម្បីដោះស្រាយបញ្ហាស្ត្រីនិងកុមារ ក៏មានគណបក្សមួយចំនួនមិនបានដាក់ចេញនូវគោលនយោបាយដាច់ដោយឡែកក្នុងការឆ្លើយតបទៅនឹងបញ្ហាស្ត្រីនិងកុមារផងដែរ។ តំណាងគណបក្សនយោបាយខ្លះក៏មិនបានលើកឡើងពីបញ្ហាប្រព័ន្ធកូតា ដើម្បីបង្កើនចំនួនតំណាងស្ត្រីក្នុងនយោបាយ ហើយក៏មិនមានការប្តេជ្ញាអ្វីជាក់លាក់ដើម្បីកំណែទម្រង់ច្បាប់ស្តីពីការបោះឆ្នោតដែរ។

តាមការពិភាក្សានេះ សង្គមស៊ីវិលសូមស្នើឲ្យគណបក្សនយោបាយទាំងអស់បង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយដាច់ដោយឡែកដើម្បីឆ្លើយតបទៅនឹងបញ្ហាស្ត្រី និង កុមារ សម្រាប់រដ្ឋសភានីតិកាលទី៥នេះ។ សង្គមស៊ីវិលសូមស្នើនូវអនុសាសន៍មួយចំនួនដែលគួរបញ្ចូលក្នុងគោលនយោបាយរបស់គណបក្ស មានដូចខាងក្រោម៖

- ការអនុវត្តន៍យកប្រព័ន្ធកូតាយេនឌ័រស្ម័គ្រចិត្តក្នុងបទបញ្ជាផ្ទៃក្នុងគណបក្សនយោបាយដែលជាយន្តការបន្ទាន់ដើម្បីបង្កើនចំនួនបេក្ខជនស្ត្រី និងចំនួនស្ត្រីក្នុងគណៈកម្មាធិការគ្រប់គ្រងរបស់គណបក្សនយោបាយ ព្រមទាំងរចនាសម្ព័ននៃការសម្រេចចិត្តរបស់គណបក្សនយោបាយផងដែរ ។
- គាំទ្រលើកំណែទម្រង់ច្បាប់ស្តីពីការបោះឆ្នោតដោយតម្រូវឲ្យមានដាក់បញ្ចូលកូតាសម្រាប់បេក្ខជនឈរឈ្មោះជាចាំបាច់ ដើម្បីធានាឲ្យមានតំណាងស្ត្រីនៅគ្រប់លំដាប់នៃការគ្រប់គ្រង និងគ្រប់លំដាប់ថ្នាក់នយោបាយ។
- ការប្រើប្រាស់បណ្តាញផ្សព្វផ្សាយឲ្យមានប្រសិទ្ធិភាពក្នុងការលើកកម្ពស់សិទ្ធិស្ត្រី សិទ្ធិកុមារដើម្បីធានាក្នុងការទទួលបានយុត្តិធម៌ និងដើម្បីលើកស្ទួយសេរីភាពខាងការបញ្ចេញមតិ និងការទទួលបានព័ត៌មានពេញលេញ ។
- ការផ្តល់ជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រីនូវប្រភពបណ្តាញផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយគ្រប់មូលដ្ឋានទូទាំងប្រទេស ក្នុងគោលបំណងលើកទឹកចិត្តឲ្យស្ត្រីចូលរួមក្នុងវិស័យនយោបាយ

លើកកម្ពស់សមភាពយេនឌ័រ និង គ្មានការរើសអើង ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងបង្កើនព័ត៌មានអំពីការថែរក្សាសុខភាព។

- ពង្រឹងអំណាចនីតិបញ្ញត្តិ និងការអនុវត្តន៍ច្បាប់ឲ្យមានលក្ខណៈល្អប្រសើរឡើងក្នុងការការពារស្ត្រីដែលរងគ្រោះដោយសារបញ្ហាចំណាកស្រុក ការជួញដូរ ការរំលោភសេពសន្ថវៈ អំពើហិង្សាដោយផ្អែកលើយេនឌ័រ ដើម្បីលុបបំបាត់នូវវប្បធម៌និទណ្ឌភាពដែលកើតមានឡើងលើបទឧក្រិដ្ឋទាំងនេះ និងដាក់ទោសទណ្ឌចំពោះជនទាំងឡាយណាដែលរំលោភលើតួនាទីនិងភារកិច្ចរបស់ខ្លួន។
- ផ្តល់ឲ្យស្ត្រីទទួលបានការអប់រំកាន់តែប្រសើរឡើង ដែលជាមធ្យោបាយដើម្បីបង្កើនឱកាសនិងសមត្ថភាពស្ត្រីក្លាយជាអ្នកតំណាងក្នុងនយោបាយនៅគ្រប់លំដាប់ថ្នាក់ និងគ្រប់វិស័យផងដែរ និង
- អនុវត្តយុទ្ធសាស្ត្រជាក់លាក់ដើម្បីទប់ស្កាត់អាត្រាក្មេងស្រីបោះបង់ចោលការសិក្សាកំរិតខ្ពស់។

ឆ្លើយតបទៅនឹងដំណើរការនេះ គណៈកម្មការរៀបចំមានប្រសាសន៍ថាៈ *"យើងជឿជាក់ថាវេទិកាពិភាក្សានេះគឺជាឱកាសដ៏សំខាន់សម្រាប់អ្នកបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចចិត្ត ថាតើគណបក្សណាដែលមានចែងពីវិធានការពិសេសដើម្បីដោះស្រាយបញ្ហាស្ត្រីនិងកុមារនៅកម្ពុជានៅក្នុងកម្មវិធីនយោបាយគណបក្សរបស់ខ្លួន មុននឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាថ្ងៃទី២៨ ខែកក្កដា ២០១៣។ យើងសូមលើកទឹកចិត្តដល់ម្ចាស់ឆ្នោតទាំងអស់ចូលរួមទៅបោះឆ្នោតទៅតាមឆន្ទៈ ឬ មនសិការរបស់ខ្លួនពិតប្រាកដ។"*

វេទិកាពិភាក្សានេះរៀបចំឡើងដោយមានកិច្ចសហការពី គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា ("ខុមហ្វ្រែល") មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ("គសន") អង្គការអន្តរជាតិអេស្បាញ សន្តិភាពនិងអភិវឌ្ឍន៍("PYD") អង្គការចំរើនស្ត្រី ("WfP") និងក្រុមស្ត្រីដើម្បីទាំងអស់គ្នា នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។ វេទិកានេះមានគោលបំណងផ្តល់ឲ្យគណបក្សនយោបាយនូវវេទិកាជជែកពិភាក្សាអំពីកម្មវិធីនយោបាយគណបក្សទាក់ទងនឹងការដោះស្រាយចំពោះបញ្ហាស្ត្រី និងកុមារ និងឆ្លើយតបទៅនឹងបញ្ហាដែលអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលបានរកឃើញក្នុងកិច្ចពិភាក្សានិងសកម្មភាពអភិវឌ្ឍន៍ជាច្រើនជាមួយប្រជាពលរដ្ឋកន្លងមក។ វេទិកានេះក៏មានគោលបំណងផ្តល់ឱកាសឲ្យអង្គការ សង្គមស៊ីវិល និងប្រជាពលរដ្ឋទទួលបានព័ត៌មានដែលបង្ហាញពីភាពចាំបាច់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ព្រមទាំងដើម្បីធានាថាឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងសកម្មភាព ទាក់ទងនឹង សិទ្ធិស្ត្រី និងកុមារ។

**ព័ត៌មានបន្ថែម សូមទាក់ទងៈ**


លោកស្រី **សឺនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល តាមរយៈលេខទូរស័ព្ទ +855 (0)17 49 40 04 ឬ អ៊ីម៉ែលៈ sereyleak@comfrel.org

លោកស្រី **ម៉ែន វណ្ណារី** មន្ត្រីសម្របសម្រួលកម្មវិធីនៃ គសន តាមរយៈលេខទូរស័ព្ទ +855 (0)16 949 997 ឬ អ៊ីម៉ែលៈ pc@cpwp.net

លោកស្រី **ជវ ច័ន្ទធីតា** អ្នកសម្របសម្រួលគម្រោងលើកស្ទួយសមាសភាពស្ត្រីក្នុងវិស័យនយោបាយនៅកម្ពុជានៃ ម.ស.ម.ក តាមរយៈលេខទូរស័ព្ទ +855(0)12 515 506 ឬ អ៊ីម៉ែលៈ thyda@cchrcambodia.org